NSW GOVERNMENT | Department of Primary Industries

ប័ណ្ណព័ត៌មាន 1

# រក្សាវាឲ្យបានស្អាតសំរាប់ទីវាលដាំបន្លែ

## ការពារកុំឲ្យមានសត្វចង្រៃ និងជម្ងឺនៅលើទីវាលដាំបន្លែ

Virginia Brunton & Jeremy Badgery-Parker, Ourimbah

ប័ណ្ណព័ត៌មានមួយឈុតនេះ បានបង្កើតឡើងដើម្បីផ្តល់ការណែនាំដ៏មានប្រយោជន៍ សំរាប់ជួយឲ្យលោកអ្នកប្រើប្រាស់យុទ្ធសាស្រ្តរួមបញ្ចូលការត្រួតពិនិត្យ និងការពារដោយសន្សំសំចៃ និងឲ្យមានប្រសិទ្ធិភាពដើម្បីគ្រប់គ្រងសត្វចង្រៃក្នុងដំណាំរបស់លោកអ្នក។ អនាម័យចំការគឺជាមូលដ្ឋាននៃការគ្រប់គ្រងការពារ។

**សត្វចង្រៃ** គឺជាអតិសុខុមប្រាណដែលធ្វើឲ្យខូចខាត ឬខាតបង់ ឬនាំឲ្យមានហានិភ័យដល់ដំណាំរបស់លោកអ្នក។ ជាញឹកញាប់បំផុត មនុស្សទាំងឡាយតែងគិតថាសត្វចង្រៃគឺជាសត្វល្អិត និងចៃ។ ទោះជាយ៉ាងនេះក្តី ពុំមែនសត្វល្អិត ឬចៃទាំងអស់សុទ្ធតែជាសត្វចង្រៃនោះឡើយ ហើយសត្វល្អិត និងចៃខ្លះក៏មានគុណប្រយោជន៍ ហើយជួយដល់ការគ្រប់គ្រងសត្វចង្រៃផងដែរ។ សត្វធំៗទាំងឡាយដូចជាកណ្តុរប្រែង កណ្តុរតូចៗ និងទន្សាយជាដើម ក៏ជាសត្វចង្រៃដែរ។

**បាក់តេរីដែលបណ្តាលឲ្យកើតជម្ងឺ** គឺជាអតិសុខុមប្រាណដែលបណ្តាលឲ្យកើតជម្ងឺ។ ជម្ងឺគឺជារោគណាមួយក្នុងរុក្ខជាតិដែលរារាំងការបំពេញមុខងារការលូតលាស់ និង?ឬការរីកចំរើនធម្មតារបស់រុក្ខជាតិ។ ដើម្បីឲ្យងាយយល់ ការបោះពុម្ពផ្សាយនេះបានប្រើពាក្យ “ជម្ងឺ” ដើម្បីយោងសំដៅទៅលើជម្ងឺទាំងពីរ គឺជម្ងឺដែលបណ្តាលឲ្យកើតមានអតិសុខុមប្រាណ និងជម្ងឺដែលអតិសុខុមប្រាណបង្កើតឲ្យមាន។

**រុក្ខជាតិតូចៗឥតប្រយោជន៍**
គឺជារុក្ខជាតិដុះនៅតាមទីកន្លែងដែលគេពុំត្រូវ ការវា។ រុក្ខជាតិតូចៗឥតប្រយោជន៍ផ្តល់ជាជំរកដល់សត្វចង្រៃ និងជម្ងឺង ទៀតដែលបន្ទាប់មកអាចចូលទៅក្នុងដំណាំ ហើយនៅក្នុងស្ថានភាពខ្លះ រុក្ខជាតិតូចៗឥតប្រយោជន៍អាចប្រណាំងប្រជែងផ្ទាល់ជាមួយដំណាំ ដើម្បីស្រូបយកទឹក និងសារធាតុចិញ្ចឹមទៀតផង។

### ការកាត់បន្ថយថ្លៃចំណាយ និងការខាតបង់

ការចំណេញ និងទិន្នផលចំការរបស់លោកអ្នកអាចប្រសើរច្រើនដោយសារការកាត់បន្ថយការខាតបង់បណ្តាលមកពីសត្វចង្រៃ ដូចជាសត្វល្អិត ចៃ ជម្ងឺ និងរុក្ខជាតិតូចៗឥតប្រយោជន៍ឲ្យមានចំនួនតិចបំផុត។ ការអនុវត្តន៍គ្រប់គ្រងសត្វចង្រៃដែលមានប្រសិទ្ធិភាព ពេលណាបានបង្កើតហើយនោះវាទំនងជាជួយកាត់បន្ថយថ្លៃចំណាយលើសារធាតុគីមី និងថ្លៃពលកម្មសរុបទាំងអស់។

ការគ្រប់គ្រងការពារសត្វចង្រៃ គឺជាការរៀបចំផែនការ ការលាងសំអាត និងការដាក់ឲ្យនៅដាច់ពីគេដើម្បីបង្ការរោគ។ ការនេះតម្រូវឲ្យមានការរៀប

ចំចាត់ចែង ភាពសមស្របគ្នា និងការប្រើប្រាស់ផែនការពាក់ព័ន្ធសំរាប់ចំការរបស់លោកអ្នក។ ផែនការដែលល្អនឹងធានារ៉ាប់រងថាលោកអ្នកអាច ១) រក្សាកន្លែងដាំបណ្តុះ និងគ្រឿងបរិក្ខារឲ្យបានស្អាត និង ២) ប្រើប្រាស់ការអនុវត្តន៍ដែលចាំបាច់ ដើម្បីបញ្ឈប់កុំឲ្យសត្វចង្រៃចូលទៅក្នុងដំណាំរបស់លោកអ្នកបាន។ ការការពារ ចំណាយតិចជាងការព្យាបាល។

ពុំមានការអនុវត្តន៍តែមួយគត់ណាមួយ ដែលអាចការពារសត្វចង្រៃបានទាំងស្រុង ដើម្បីកុំឲ្យវាធ្វើឲ្យខាតបង់ដល់ផលដំណាំ និងអាជីវកម្មរបស់លោកអ្នកឡើយ។ មានយុទ្ធសាស្រ្ត និងជំរើសនៃការត្រួតពិនិត្យដ៏ជាក់លាក់ ឬមធ្យោបាយផ្សេងៗគ្នាជាច្រើនដែលអាចប្រើនៅក្នុង និងជុំវិញចំការដើម្បីគ្រប់គ្រងលើបញ្ហាសត្វចង្រៃ។

ជំរើសនីមួយៗនឹងទោរទន់ទៅរក:

- ការប៉ះទង្គិចផ្សេងៗគ្នា
- ប៉ះពាល់ដល់សត្វចង្រៃ និងជម្ងឺផ្សេងៗគ្នា
- មានថ្លៃចំណាយ ឬគុណប្រយោជន៍ផ្សេងៗគ្នា។

គន្លឹះដែលសំខាន់ ដើម្បីឲ្យថ្លៃចំណាយលើការគ្រប់គ្រងសត្វចង្រៃមានប្រសិទ្ធិភាព គឺការរួមបញ្ចូលនូវយុទ្ធសាស្រ្តសក្តិសមបំផុត មកពីជំរើសល្អបំផុតដែលអាចមាន និងការបង្កើតឲ្យមានជាកម្មវិធីការពារដ៏រឹងមាំមួយ។

### វិធីសាស្រ្តរួមបញ្ចូលការគ្រប់គ្រងលើសត្វចង្រៃ

IPM(វិធីសាស្រ្តរួមបញ្ចូលការគ្រប់គ្រងលើសត្វចង្រៃ) គឺជាការប្រើមធ្យោបាយច្រើនយ៉ាង ដើម្បីបង្ក្រាបសត្វចង្រៃឲ្យនៅត្រឹមកំរិតដែលអាចទ្រាំទ្របាន។ ការនេះមានន័យថា ការប្រើមធ្យោបាយច្រើនជាងមួយ ការអនុវត្តន៍ ឬវិធានការត្រួតពិនិត្យដោយរួមផ្សំគ្នា។ វាក៏មានន័យដែរថាគោលបំណងពុំមែនដើម្បីបំបាត់បញ្ហាជាប្រចាំនោះឡើយ ដោយព្រោះថាជួនកាលវាអាចមានផលប្រយោជន៍ច្រើនជាង ក្នុងការទ្រាំទ្រនឹងសត្វចង្រៃមួយចំនួនតូច ឬជម្ងឺក្នុងកំរិតខ្សោយមួយ ជាជាងចំណាយប្រាក់ច្រើនដើម្បីបំបាត់បញ្ហាឲ្យបានទាំងស្រុង។

ចំណុចសំខាន់ដែលត្រូវចងចាំគឺ "ការរួមបញ្ចូលគ្នា"។ ការរួមផ្សំរវាងមធ្យោបាយសមរម្យ ឬការអនុវត្តន៍ដែលបានប្រើ ត្រូវដាក់ជាមួយគ្នាដោយសមហេតុសមផលចំពោះអាជីវកម្មរបស់លោកអ្នក។

> *" វិធីសាស្ត្ររួមបញ្ចូលការគ្រប់គ្រងលើសត្វចង្រៃ គឺជាការប្រើមធ្យោបាយច្រើនយ៉ាងដើម្បីបង្ក្រាបសត្វចង្រៃ ឲ្យនៅត្រឹមកំរិតដែលអាចទ្រាំទ្របាន "*

ប័ណ្ណពត៌មានទាំង១០ដែលមាននៅក្នុងឈុត "រក្សាវាឲ្យបានស្អាតសំរាប់ទីវាលដាំបន្លែ" ផ្តោតទៅលើការអនុវត្តន៍ការពារដែលអាចប្រតិបត្តិការបានរហូតដល់ចំណុចនៃការអនុវត្តន៍ត្រួតពិនិត្យ ដូចជាការប្រើវិធីព្យាបាលផ្នែកជីវសាស្ត្រ ឬដោយប្រើសារធាតុគីមីជាដើម។

## តើលោកអ្នកចាប់ផ្តើមដោយរបៀបណា?

មនុស្សគ្រប់រូបអាចអនុវត្តន៍ IPM។ វាទាំងអស់នេះគឺអំពីការប្រើមធ្យោបាយ និងការអនុវត្តន៍ផ្សេងៗគ្នាមួយចំនួនដោយរួមផ្សំគ្នា។ កន្លែងដែលសំខាន់ជាងគេ ហើយមានតម្លៃថោកបំផុតសំរាប់ចាប់ផ្តើមកិច្ចការ គឺជាមួយនឹងការការពារ – រក្សាវាឲ្យបានស្អាត។

ការរៀបចំកម្មវិធីសំរាប់ការគ្រប់គ្រងការពារដែលមានប្រសិទ្ធិភាព នឹងតម្រូវឲ្យ:

- ដឹងពីរបៀបយ៉ាងណា និងនៅកន្លែងណាដែលបញ្ហាកើតឡើង។
- ប្រើប្រាស់ការអនុវត្តន៍ឲ្យបានច្រើនបំផុត តាមលទ្ធភាពធ្វើបានដើម្បីកាត់បន្ថយហានិភ័យ ដោយសារការកើតឡើងយ៉ាងទាន់ហន់នៃសត្វល្អិតចង្រៃ និងជម្ងឺក្នុងដំណាំរបស់លោកអ្នក។
- ធ្វើការវាយតម្លៃលើហានិភ័យ កើតឡើងដោយសារសត្វចង្រៃនីមួយៗ ហើយប្រើពត៌មាននេះ ដើម្បីរៀបចំផែនការឲ្យមានសណ្តាប់ធ្នាប់បំផុត សំរាប់ប្រតិបត្តិការយុទ្ធសាស្ត្រការពារទាំងអស់ដែលលោកអ្នកអាចធ្វើបាន។

> *" ប្រើមធ្យោបាយ និងការអនុវត្តន៍ឲ្យបានច្រើនបំផុត តាមលទ្ធភាពធ្វើបាន "*

ការវាយតម្លៃលើហានិភ័យ និងការរៀបចំផែនការ ផ្តល់ឲ្យលោកអ្នកនូវពេលវេលាដើម្បីរៀបចំ និងការពារ ឬយ៉ាងហោចណាស់កំរិតការខូចខាត និងថ្លៃចំណាយលើសត្វចង្រៃ និងជម្ងឺ។ ប្រសិនបើលោកអ្នកពុំបានអនុវត្តអនាម័យល្អ និងប្រើយុទ្ធសាស្ត្រការពារទេ វានឹងមានការពិបាកច្រើនជាប្រចាំ និងអស់ថ្លៃចំណាយច្រើន ដើម្បីឲ្យអាចគ្រប់គ្រងលើបញ្ហាសត្វចង្រៃណាមួយ។

**យ៉ាងតិចណាស់មានការអនុវត្តន៍គ្រប់គ្រងសំខាន់ៗចំនួន១០យ៉ាង ដែលចាំបាច់ត្រូវប្រើក្នុងគ្រប់ចំការនីមួយៗ។ បើទោះបីជាលោកអ្នកពុំធ្វើអ្វីផ្សេងទៀតក៏ដោយ សូមធ្វើកិច្ចការទាំងអស់នេះ:**

១. ការឆែកមើលសត្វចង្រៃ និងជម្ងឺត្រូវចាត់ចែងធ្វើជាទម្លាប់ដើម្បីឲ្យបានច្បាស់ប្រាកដថាមានការរកឃើញទាន់ពេល និងការសម្គាល់ដឹងបញ្ហាបានត្រឹមត្រូវ។

២. ត្រូវប្រើពត៌មានអំពីការពិនិត្យតាមដានដំណាំ សំរាប់ធ្វើការសម្រេចចិត្តទាំងឡាយ មានរួមទាំងការព្យាបាលដោយជាតិគីមី ខាងជីវសាស្ត្រ ដំណាំទាំងមូល និងកន្លែងដែលមានសីតុណ្ហភាពខ្ពស់។

៣. ត្រូវបញ្ជូនចេញសត្វល្អិតដែលពុំស្គាល់ ឬរុក្ខជាតិដែលមានរោគសញ្ញាជម្ងឺ ដើម្បសម្គាល់ឲ្យបានដឹង។

៤. ត្រូវរក្សាកន្លែងផលិតភោគផលដំណាំ និងចំការដែលនៅជុំវិញកុំឲ្យមានរុក្ខជាតិតូចៗឥតប្រយោជន៍ដុះ។

៥. កន្លែងដាំដុះគឺនៅក្នុងតំបន់ "ស្អាត" ដែលត្រូវបានដាក់ឲ្យនៅដាច់ពីតំបន់ "ខាងក្រៅ" ចំការ ដើម្បីបង្ការកុំឲ្យឆ្លងរោគ។

៦. ត្រូវដាក់កូនរុក្ខជាតិតូចៗទាំងអស់ឲ្យនៅដាច់ពីគេ ដើម្បីបង្ការកុំឲ្យឆ្លងរោគ ឆែកមើល ហើយកុំឲ្យមានសត្វចង្រៃ និងជម្ងឺ មុននឹងដាំបណ្តុះកូនរុក្ខជាតិតូចៗ។

៧. ត្រូវដាំគ្រាប់ពូជ ឬកូនរុក្ខជាតិតូចៗនៅក្នុងកន្លែងដាំបណ្តុះស្អាតដែលពុំមានដាំដំណាំអម្បូរដូចគ្នានឹងដំណាំឆ្នាំមុន (ឬនាំមកនូវជម្ងឺដុះផ្សិត ដែលជារឿយៗបង្ករឡើងតាមដីដូចជា sclerotinia ជាដើម)។

៨. ដាំបណ្តុះដំណាំចាស់ៗទៅក្នុងដីជាបន្ទាន់ បន្ទាប់ពីការច្រូតកាត់ប្រមូលផល ឬបានបោះបង់ចោល។

៩. សកម្មភាពរបស់មនុស្ស ឬត្រាក់ទ័រត្រូវមានតិចបំផុត នៅពេលស្លឹកដំណាំវាសើម ជាពិសេសនៅពេលដែលដំណាំបង្ហាញឲ្យឃើញនូវសញ្ញានៃជម្ងឺដុះផ្សិត ឬជម្ងឺបាក់តើរនៅលើស្លឹក។

១០. ត្រូវរៀបគ្រោងសកម្មភាពទាំងឡាយ ក្នុងដំណាំដែលមានសត្វចង្រៃតិចតួចបំផុត មុននឹងធ្វើកិច្ចការក្នុងដំណាំដែលមានសត្វចង្រៃច្រើន។

ការទទួលស្គាល់: ពត៌មាននៅក្នុងការបោះពុម្ពផ្សាយនេះ បានរៀបចំចេញពី រក្សាវាឲ្យបានស្អាត – កាត់បន្ថយការចំណាយ និងការខាតបង់ក្នុងការគ្រប់គ្រង សត្វចង្រៃ និងជម្ងឺនៅក្នុងរោងដាំបន្លែ និងកូនរុក្ខជាតិ។ Badgery-Parker, J and T Burfield 2009 ជាមួយនឹងគំនិត និងឱវាទបានមកពី Sandra McDougall និង Alison Anderson។

©រដ្ឋញូវសៅវែល តាមរយៈក្រសួងពាណិជ្ជកម្ម និងវិនិយោគ ហេដ្ឋារចនាសម្ព័ន្ធ ប្រចាំតំបន់ និងកិច្ចបំរើ ឆ្នាំ២០១០។ លោកអ្នកអាចចម្លង ចែកចាយ និងដោះ ស្រាយជាមួយនឹងការបោះពុម្ពផ្សាយតាមរបៀបផ្សេងពីនេះដោយសេរី ដើម្បីគោលបំណងណាមួយ គឺឲ្យតែលោកអ្នកបានបញ្ជាក់ថាក្រសួងពាណិជ្ជកម្ម និងវិនិយោគ ហេដ្ឋារចនាសម្ព័ន្ធប្រចាំតំបន់

ISSN 1832-6668

ការប្រកាសមិនទទួលខុសត្រូវ: ពត៌មាននៅក្នុងការបោះពុម្ពផ្សាយនេះ គឺសំអាងលើ ចំណេះដឹង និងការយល់ដឹងនៅក្នុងពេលកំពុងសរសេរ (ខែមីនា ឆ្នាំ២០១២)។ ទោះជាយ៉ាងនេះក្តី ដោយសារការជឿនលឿនផ្នែកចំណេះដឹង អ្នកប្រើប្រាស់ត្រូវបានរំលឹកអំពីសេចក្តីត្រូវការដើម្បីឲ្យប្រាកដច្បាស់ថា ពត៌មានដែលគេពឹងផ្អែកទៅលើមានលក្ខណៈទាន់ពេល និងសំរាប់ឆែកមើលបច្ចុប្បន្នភាពនៃពត៌មានជាមួយភ្នាក់ងារ

ចុះផ្សាយដោយក្រសួងឧស្សាហកម្មកែឆ្នៃវត្ថុធាតុដើម ដែលជាផ្នែកមួយរបស់ក្រសួង ពាណិជ្ជកម្ម និងវិនិយោគ ហេដ្ឋារចនាសម្ព័ន្ធប្រចាំតំបន់ និងកិច្ចបំរើ។

Trim reference INT 12/24522

Horticulture Australia

ការផលិតប័ណ្ណពត៌មាននេះ និងការបកប្រែភាសាបានទទួលការផ្គត់ផ្គង់ប្រាក់មួយចំណែក ពីគំរោងដែលទទួលប្រាក់ឧបត្ថម្ភរបស់ HAL អង្គការដំណាំវប្បកម្មអូស្រ្តាលី): *ការដោះស្រាយអំពីគុណភាព និងសុវត្ថិភាពនៃផលិតផល ជាមួយអ្នកដាំដុះនៃឧស្សាហកម្មបន្លែដែលនិយាយភាសាក្រៅពី ភាសាអង់គ្លេស* ការផ្តើមគំនិតនៃកម្មវិធីអភិវឌ្ឍន៍ឧស្សាហកម្មបន្លែ។